ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

**សុន្ទរកថាបើក**
**លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ថ្លែងក្នុងសិក្ខាសាលា ស្តីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និង សហគ្រិនភាពដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ"**

ថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៥

សូមគោរព៖

- ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី!

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក និងសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះការអញ្ជើញចូលរួមរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសិក្ខាកាមទាំងអស់ ក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "**ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងសហគ្រិនភាពដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ**" ដែលសហការរៀបចំដោយ ធនាគារជាតិនៃកម្ពុជា និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នាពេលនេះ។ សិក្ខាសាលានេះ គឺជាសក្ខីភាពនៃការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់សមត្ថភាពពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងសហគ្រិនភាព ដល់អ្នកប្រកបមុខរបរនិងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្នុងគោលដៅរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ភាពធន់ និងបរិយាបន្ន។

ជាការពិតណាស់សេដ្ឋកិច្ចក្រៅប្រព័ន្ធដើរតួនាទីយ៉ាងសំខាន់នៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ យោងតាមទិន្នន័យរបស់ World Economic[1] សេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាមានចំណែកប្រមាណ ៤៩,១% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ដែលបានផ្តល់ការងារដល់ប្រជាជន ទ្រទ្រង់អាជីវកម្មខ្នាតតូច និងជួយរក្សានូវចរាចរសាច់ប្រាក់ក្នុងសេដ្ឋកិច្ច។ ទោះបីជាយ៉ាង

[1] https://www.worldeconomics.com/National-Statistics/Informal-Economy/Cambodia.aspx



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

នេះក៏ដោយ អ្នកប្រកបរបរក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានជួបបញ្ហាប្រឈមជាច្រើនរួមមាន កង្វះខាតក្នុងការទទួលបានសេវាហិរញ្ញវត្ថុ កង្វះខាតការគាំពារ និងការប្រឈមនឹងភាពងាយរងគ្រោះនានាពិសេសនៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះ ឬក្នុងពេលមានវិបត្តិជាដើម។

ដើម្បីលើកកម្ពស់ និងជំរុញសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យដំណើរការប្រកបដោយសក្តានុពល រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ឱ្យដំណើរការយុទ្ធសាស្ត្រជាតិ ស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨។ ការជំរុញ និងលើកទឹកចិត្តឱ្យអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធចូលក្នុងវិស័យផ្លូវការតាមរយៈការចុះឈ្មោះ ផ្តល់នូវអត្ថប្រយោជន៍ជាច្រើនសម្រាប់អ្នកប្រកបអាជីវកម្មនិងធ្វើការងារ ក្នុងការទទួលបាននូវការការពារតាមផ្លូវច្បាប់ ការទទួលបានហិរញ្ញប្បទាននិងការប្រើប្រាស់នូវសេវាហិរញ្ញវត្ថុផ្លូវការ ការលើកទឹកចិត្តផ្នែកពន្ធដារ និងការបណ្តុះបណ្តាលជំនាញ ជាដើម។

ស្របតាមយុទ្ធសាស្ត្រជាតិខាងលើនេះ ធនាគារជាតិនៃកម្ពុជា បានអនុវត្តវិធានការមួយចំនួនសំដៅលើកកម្ពស់សមត្ថភាព និងគាំទ្រដល់អ្នកដែលបានឈានចូលក្នុងប្រព័ន្ធ ដើម្បីទទួលបានហិរញ្ញប្បទាន ព្រមទាំងការលើកកម្ពស់បរិយាបន្ននិងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដើម្បីផ្តល់លទ្ធភាពឱ្យកាន់តែទូលំទូលាយដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក៏ដូចជាបុគ្គលស្វ័យនិយោជន៍ក្នុងការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ និងចៀសវាងការប្រើប្រាស់មិនចំគោលដៅ ដែលបង្កើតជាហានិភ័យបំណុលលើសលុប។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូននូវការចូលរួមចំណែករបស់ប្រព័ន្ធធនាគារក្នុងការលើកកម្ពស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលរួមមាន៖

**១/-ការងារលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ**

ស្របតាមយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិពាក់ព័ន្ធ ក្នុងការដាក់ចេញនិងអនុវត្តនូវសកម្មភាព យុទ្ធនាការផ្សព្វផ្សាយ កម្មវិធីអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងយន្តការនានា។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជា ក្រោមកិច្ចសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ លើមុខវិជ្ជា គណិតវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជា។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បានរៀបចំសិក្ខាសាលា និងផ្សព្វផ្សាយជាសាធារណៈស្តីពី ការលើកកម្ពស់ការយល់ដឹង កិច្ចការពារអតិថិជន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ស្ថិរភាព និងតម្លាភាព ព្រមទាំងបានសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងហិរញ្ញវត្ថុឌីជីថលផងដែរ។

## ២/-ការលើកទឹកចិត្តដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងបុគ្គលស្វ័យនិយោជន៍

ធនាគារជាតិនៃកម្ពុជា បានរៀបចំនូវបទប្បញ្ញត្តិនានា និងបានដាក់ចេញសារាចរណែនាំស្តីពីការលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រួលក្នុងការបើកគណនីសន្សំ និងការផ្តល់សេវាហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងបុគ្គលស្វ័យនិយោជន៍ ដែលបានចុះបញ្ជីនៅច្រកចេញចូលតែមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត តាមរយៈការអនុវត្តប្រកាសស្តីពី "ហានិភ័យឥណទាន សម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ" បានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់ឥណទានក្នុងអត្រាការប្រាក់សមរម្យទៅសហគ្រាសធុនមីក្រូ តូច និងមធ្យម ដោយកំណត់ថ្លឹងហានិភ័យត្រឹមតែ ៧៥% *(ឯសហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលមិនបានចុះបញ្ជី កម្រិតថ្លឹងហានិភ័យស្មើនឹង ១០០%)*។ នេះមានន័យថាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានលទ្ធភាពផ្តល់ឥណទានច្រើនជាងមុន ឬអាចផ្តល់ឥណទានក្នុងអត្រាការប្រាក់ទាបជាងមុន ដល់វិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យមដែលបានចុះបញ្ជី។ លើសពីនេះ គ្រឹះស្ថានធនាគារបានបើកគណនី និងផ្តល់ជា QR code ប្រមាណ ១,៥លាន សម្រាប់ពាណិជ្ជករប្រើប្រាស់ជូនដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## ៣/-ការអភិវឌ្ឍប្រព័ន្ធទូទាត់

ធនាគារជាតិនៃកម្ពុជា បានអភិវឌ្ឍនិងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ដើម្បីសម្រួលដល់អតិថិជននិងសមាជិកក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ប្រាក់អន្តរគ្រឹះស្ថានក៏ដូចជាតាមកម្មវិធីធនាគារចល័តឬទូរស័ព្ទចល័តរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបន្តចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការទូទាត់ទំនិញនិងសេវាបានយ៉ាងងាយស្រួល រហ័ស និងប្រសិទ្ធភាព។ ប្រព័ន្ធទូទាត់សងប្រាក់របស់យើងនាពេលបច្ចុប្បន្ននេះ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធទូទាត់អន្តរជាតិ ដែលអនុញ្ញាតឱ្យប្រជាជនកម្ពុជាអាចទូទាត់និងផ្ទេរប្រាក់ឆ្លងដែនបាន ជាពិសេស ពលករនិងអ្នកប្រកបអាជីវកម្មក្រៅប្រទេស។ ការដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសថៃ ឡាវ ម៉ាឡេស៊ី វៀតណាម ចិន និងបណ្តាប្រទេសមួយចំនួនទៀត បានគាំទ្រដល់វិស័យទេសចរណ៍ ពាណិជ្ជកម្ម ដែលអនុញ្ញាតឱ្យអ្នកប្រកបមុខរបរក្រៅប្រព័ន្ធទទួលបានផលប្រយោជន៍ តាមរយៈការទូទាត់ទំនិញនិងសេវាដោយប្រើខេអេចឃ្យូរកូត។ ការអភិវឌ្ឍប្រព័ន្ធទូទាត់នេះ បានចូលរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងសម្រួលដល់ប្រតិបត្តិការទូទាត់សម្រាប់សហគ្រាស-អាជីវកម្មឱ្យកាន់តែមានប្រសិទ្ធភាព និងកាត់បន្ថយចំណាយ ស្របតាមយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ និងគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជថលរបស់រាជរដ្ឋាភិបាលឆ្នាំ២០២១-២០៣៥។

## ៤/-ការបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ស្ត្រី

ក្រោមកិច្ចសហការរវាង ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីត្រូវបានលើកកម្ពស់ ក្នុងគោលបំណងបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការដែលមានរយៈពេលអនុវត្ត ៥ ឆ្នាំ។ កិច្ចសហការនេះ មានគោលបំណងលើកកម្ពស់បរិយាបន្នវត្ថុសម្រាប់ស្ត្រីតាមរយៈការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងហិរញ្ញវត្ថុឌីជីថល ការពង្រឹងភាពធន់ផ្នែកសេដ្ឋកិច្ច និងការពង្រីកភាពជាដៃគូក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ព្រមទាំងការលើកទឹកចិត្តដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យបង្កើនការផ្តល់សេវាហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ ជាពិសេសដល់ស្ត្រី។ គួររំលេចផងដែរថា គិតត្រឹមឆ្នាំ២០២៤ ចំពោះវិស័យធនាគារ ចំនួនស្ត្រីដែលបានប្រើប្រាស់សេវាកម្ចី មានប្រមាណ ៥៩% និងចំនួនស្ត្រីដែលមានប្រាក់បញ្ញើមានប្រមាណ៥១% រីឯវិស័យមីក្រូហិរញ្ញវត្ថុ ចំនួនស្ត្រីដែលប្រើប្រាស់សេវាកម្ចីនិងមានប្រាក់បញ្ញើ ប្រមាណ ៦៤%និង៦៧% រៀងគ្នា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីមេត្រី!**

ចំណេះដឹងផ្នែកហិរញ្ញវត្ថុ សំដៅទៅលើចំណេះដឹងនិងសមត្ថភាពក្នុងការយល់ដឹងអំពីដំណើរការសន្សំនិងការចាយវាយប្រចាំថ្ងៃ។ គោលដៅចម្បងរបស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុគឺការអប់រំឱ្យមនុស្សចេះគ្រប់គ្រងថវិការបស់ខ្លួន និងយល់ពីសារៈសំខាន់អំពីការសន្សំប្រាក់និងការវិនិយោគ ដើម្បីទទួលបានសេរីភាពផ្នែកហិរញ្ញវត្ថុនិងជីវភាពធូរធារនាពេលអនាគត។ ចំណេះដឹងផ្នែកហិរញ្ញវត្ថុគឺពុទ្ធិដែលមិនអាចខ្វះបានចំពោះមនុស្សគ្រប់វ័យ ពីព្រោះមនុស្សគ្រប់រូបត្រូវប្រើប្រាស់ប្រាក់ជារៀងរាល់ថ្ងៃ។

តាមរយៈសិក្ខាសាលាថ្ងៃនេះ យើងមានគោលបំណងជំរុញការយល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពីគោលការណ៍ហិរញ្ញវត្ថុ លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងលើកទឹកចិត្តដល់ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយទំនួលខុសត្រូវ ហើយយើងក៏អាចបង្កើតវេទិកាដែលអាចអនុញ្ញាតឱ្យបុគ្គលនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចចូលរួមយ៉ាងសកម្មនៅក្នុងប្រព័ន្ធអេកូហិរញ្ញវត្ថុរបស់កម្ពុជា។ ខ្ញុំសូមលើកទឹកចិត្តឱ្យសិក្ខាកាមទាំងអស់យកចិត្តទុកដាក់ និងចូលរួមឱ្យបានសកម្មជាគំនិត យោបល់ និងកិច្ចពិភាក្សា ដើម្បីជាប្រយោជន៍សម្រាប់ជាធាតុចូលក្នុងការរៀបចំ និងអនុវត្តគោលនយោបាយពាក់ព័ន្ធនានា។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ ក៏ដូចជាក្រុមការងារបច្ចេកទេសនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងធនាគារជាតិនៃកម្ពុជា ចំពោះកិច្ចសហការយ៉ាងជិតស្និទ្ធលើគំនិតផ្តួចផ្តើមនេះ ដែលជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការកសាងសេដ្ឋកិច្ចជាតិប្រកបដោយស្ថិរភាព និងបរិយាបន្ន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញានិងភ្ញៀវកិត្តិយស ទាំងអស់ សូមសមប្រកបពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលា ស្តីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងសហគ្រិនភាព ដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ" ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**